# នីតិវិធីសម្រាប់ដំណើរការនៃការដាក់ពាក្យបណ្តឹងអំពីការបញ្ជូនទៅកម្មវិធី AEDY

I. គោលបំណង៖

ដើម្បីផ្តល់នូវ នីតិវិធី និង គោលការណ៍ណែនាំទូទៅ សម្រាប់ដំណើរការនៃការដាក់ពាក្យបណ្តឹងរបស់ ឪពុកម្តាយ/អាណាព្យាបាល អំពីការបញ្ជូនទៅកម្មវិធី AEDY នៅក្នុងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។

II. ការទទួលខុសត្រូវ៖

ការិយាល័យ សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស ទទួលខុសត្រូវចំពោះការ ពិនិត្យ និង ស៊ើបអង្កេត បញ្ហា និង សេចក្តីសម្រេច ដែលធ្វើឡើងដោយ បុគ្គលិកសាលា និង/ឬ បុគ្គលិកការិយាល័យកណ្តាល ដើម្បីបញ្ជាក់ថាតើសេចក្តីសម្រេចនោះបានធ្វើឡើងស្របតាម ច្បាប់ នីតិវិធី និង ការអនុវត្តន៍ របស់ក្រសួងអប់រំដែរឬទេ។

III. អ្វីៗដែលអាចត្រូវគេពិនិត្យឡើងវិញ៖

១. ការផ្លាស់ប្តូរសាលាដោយសារការដាក់វិន័យ - ការផ្លាស់ប្តូរសាលាបានធ្វើឡើងស្របតាមសវនានៃការដាក់វិន័យ
២. ការចាត់តាំងបណ្តោះអាសន្នឱ្យទៅសាលាដែលមានវិន័យតឹងរឹង ដើម្បីសុវត្ថិភាព - ការផ្លាស់ប្តូរសាលាបានធ្វើឡើងដោយការយកចិត្តទុកដាក់លើសុវត្ថិភាពដែលជះឥទ្ធិពលដល់សហគមន៍សាលា
៣. ទិដ្ឋភាពដែលទាក់ទងនឹងកម្មវិធី AEDY

IV. លក្ខណៈវិនិច្ឆ័យ៖

នៅក្នុងពាក្យបណ្តឹងទាំងអស់ កត្តាដែលបុគ្គលិកការិយាល័យ សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស នឹងពិចារណា រួមមាន ប៉ុន្តែគ្មានកំណត់ចំពោះ៖

១. តើគេបានអនុវត្តតាម ច្បាប់ និង នីតិវិធី ទាំងអស់នោះដែរឬទេ
២. តើគេបានរំលោភសិទ្ធិរបស់ក្មេងដែរឬទេ
៣. សុខភាព សុវត្ថិភាព និង សុខុមាលភាព របស់ ក្មេង និង សហគមន៍សាលា។

V. ដំណើរការសម្រាប់ពាក្យបណ្តឹង

១. សម្រាប់រាល់បញ្ហាដែលបានរៀបរាប់ខាងលើ សូមបំពេញលិខិតបែបបទដែលបានភ្ជាប់មកជាមួយ ហើយប្រគល់ទៅឱ្យការិយាល័យ សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស ក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃក្នុងប្រតិទិន នៃសេចក្តីសម្រេច ដោយផ្ទាល់នៅអាស័យដ្ឋានលេខ ៤៤០ ផ្លូវ N. Broad ជាន់ទី ២ ឬ តាមអ៊ីមែល (studentrights@philasd.org) រួមជាមួយ*ឯកសារពាក់ព័ន្ធទាំងអស់។*
២. នៅក្នុងពាក្យបណ្តឹងទាំងអស់ បុគ្គលិកការិយាល័យ សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស នឹងពិនិត្យមើលលិខិតបែបបទ និង ឯកសារដែលភ្ជាប់មកជាមួយ។ បើសិនជាគេត្រូវការឯកសារអ្វីបន្ថែមទៀតដើម្បីធ្វើសេចក្តីសម្រេច សាលា ឬ ការិយាល័យកណ្តាល នឹងធ្វើការស្នើសុំ។
៣. នៅពេលគេបានទទួលឯកសារទាំងអស់ហើយ បុគ្គលិកនឹងពិនិត្យមើលឯកសារទាំងអស់ ហើយធ្វើសេចក្តីសម្រេចក្នុងរយៈពេល ២១ ថ្ងៃ នៃថ្ងៃក្នុងប្រតិទិន។
៤. អ្នកដែលមាន បណ្តឹងតវ៉ា និង ការព្រួយបារម្ភ ដែលទាក់ទងនឹងកម្មវិធី AEDY គេតម្រូវឱ្យស្វែងរកដំណោះស្រាយតាមរយៈ កម្មវិធី AEDY និង/ឬ LEA ដែលពាក់ព័ន្ធ ជាមុនសិន ជាជាងជំរុញការព្រួយបារម្ភនេះទៅកាន់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនីញ៉ា។ កម្មវិធី AEDY និង ក្រសួងអប់រំ នឹងសហការគ្នាដើម្បីដោះស្រាយការព្រួយបារម្ភនានា ទៅតាមលក្ខណៈសមរម្យ។
៥. នឹងគ្មានសវនាការទេ ហើយសេចក្តីសម្រេច/ដំណោះស្រាយ នឹងធ្វើឡើងដោយផ្អែកលើឯកសារដែលគេបានដាក់ជូន។ គេនឹងផ្តល់ដំណឹងជូនដល់ សមាជិកសហគមន៍ និង/ឬ ឪពុកម្តាយ និង សាលា អំពីសេចក្តីសម្រេច/ដំណោះស្រាយ នេះ។ គេក៏នឹងជូនដំណឹងអំពី សេចក្តីសម្រេច/ដំណោះស្រាយ នេះដល់ អគ្គនាយករង និង/ឬ ការិយាល័យកណ្តាលដែលពាក់ព័ន្ធ ផងដែរ។

ច្បាប់ដែលពាក់ព័ន្ធ

១១៨៖ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស

# លិខិតដាក់ពាក្យបណ្តឹងរបស់ មាតាបិតា/អាណាព្យាបាល

## សម្រាប់ ការចាត់តាំងដោយការដាក់វិន័យ (AEDY) ឬ ការចាត់តាំងបណ្តោះអាសន្នដោយការដាក់វិន័យ (AEDY)

ឪពុកម្តាយ/អាណាព្យាបាលសិស្ស របស់ក្រសួងអប់រំ មានសិទ្ធិលើកឡើងពីការព្រួយបារម្ភរបស់ពួកគេដែលទាក់ទងនឹងបញ្ហាដូចតទៅនេះ៖ ១) ការចាត់តាំងឱ្យទៅកម្មវិធី AEDY ណាមួយ ២) សេចក្តីសម្រេចដកចេញពីកម្មវិធី AEDY ណាមួយ ៣) គុណភាពនៃការបង្ហាត់បង្រៀនរបស់កម្មវិធី AEDY ៤) ការផ្តល់ ឬ ការលុបចោល ជំនួយភាសានៅក្នុងកម្មវិធី AEDY ៥) ការបម្រើសិស្សពិការ ដែលអាចរួមបញ្ចូលការកែសម្រួលសមហេតុផល ក្នុងខណៈពេលនៅក្នុងកម្មវិធី AEDY ។ ដើម្បីដាក់ពាក្យបណ្តឹង សូមបំពេញលិខិតបែបបទនេះ ហើយប្រគល់ឱ្យដោយផ្ទាល់នៅអាស័យដ្ឋានលេខ ៤៤០ ផ្លូវ N. Broad បន្ទប់លេខ ២៤៣ ឬ តាមរយៈអ៊ីម៉ែលទៅ studentrights@philasd.org ។ សូមមើលនីតិវិធីដែលបានភ្ជាប់មកជាមួយ ជាជំនួយក្នុងការបំពេញលិខិតបែបបទនេះ។

ថ្ងៃខែ/ Date: ____________________________

ឈ្មោះ មាតាបិតា/អាណាព្យាបាល/ Parent/Guardian Name: ____________________________

អាស័យដ្ឋាន/អង្គការ/ Address/Agency: ____________________________

លេខទូរស័ព្ទ/ Phone Number: ____________________________

លេខទូរស័ព្ទផ្សេងទៀត/Additional Nmber: ____________________________

អ៊ីមែល/ Email address: ____________________________

ឈ្មោះសិស្ស/ Name of Student: ____________________________

ថ្ងៃខែឆ្នាំកំណើត ឬ អត្តលេខ/ DOB or ID: ____________________________

**តើបច្ចុប្បន្ននេះក្មេងមានទទួលជំនួយអ្វីមួយដូចខាងក្រោមនេះឬទេ?**

(គូសប្រអប់ដែលពាក់ព័ន្ធ)

☐ 504 Service Agreements

☐ Individualized Education Plan (IEP)

☐ English Learners (EL)

**សូមគូសប្រភេទនៃសេចក្តីសម្រេចដែលលោកអ្នកប្តឹងសារទុក្ខ៖**

☐ ការចាត់តាំងដោយការដាក់វិន័យឱ្យទៅ កម្មវិធី AEDY (Camelot)

☐ ការចាត់តាំងបណ្តោះអាសន្នដោយការដាក់វិន័យឱ្យទៅ កម្មវិធី AEDY (Camelot)

☐ ផ្សេងៗ៖ ____________________________

**តើលោកអ្នកមានបញ្ហាអ្វី? រៀបរាប់អំពីបញ្ហាដែលលោកអ្នកចង់ឱ្យគេដោះស្រាយ។**

**តើលោកអ្នកចង់បានលទ្ធផលបែបណា?**

**កំណត់សម្គាល់៖** ដើម្បីបំពេញលិខិតបែបបទនេះ សូមភ្ជាប់មកជាមួយនូវឯកសារទាំងអស់ដែលគាំទ្រលទ្ធផលដែលលោកអ្នកចង់បាន។